# សុន្ទរកថារបស់
# ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស
# និងសហប្រតិបត្តិការអន្តរជាតិ
# ថ្លែងក្នុងឱកាសសម័យប្រជុំលើកទី៨០ នៃមហាសន្និបាតអង្គការសហប្រជាជាតិ
# មូលបទ «រួមគ្នាដើម្បីភាពប្រសើរឡើង៖ ៨០ឆ្នាំ និងច្រើនឆ្នាំទៀត ដើម្បីសន្តិភាព ការអភិវឌ្ឍ និងសិទ្ធិមនុស្ស»

*********

លោកជំទាវប្រធាន

ឯកឧត្តម លោកជំទាវ និងប្រតិភូទាំងអស់ជាទីរាប់អាន

ខ្ញុំសូមចាប់ផ្តើមដោយសម្តែងអំណរសាទរយ៉ាងកក់ក្តៅជូន លោកជំទាវ Annalena Baerbock ដែលបានជាប់ឆ្នោតជាប្រធានសម័យប្រជុំលើកទី៨០ នៃមហាសន្និបាតអង្គការសហប្រជាជាតិ។ ខ្ញុំសូមកោតសរសើរឯកឧត្តម Philemon Yang ចំពោះការដឹកនាំដ៏ឈ្លាសវៃរបស់ឯកឧត្តមក្នុងអំឡុងសម័យប្រជុំលើកទី៧៩ របស់អង្គការសហប្រជាជាតិ។ **កតិកាសញ្ញាសម្រាប់អនាគត** ដែលត្រូវបានអនុម័តក្នុងអំឡុងអាណត្តិរបស់ឯកឧត្តម បានក្លាយជាមូលដ្ឋានសម្រាប់មូលបទនៅក្នុងឆ្នាំនេះ **«រួមគ្នាដើម្បីភាពប្រសើរឡើង៖ ៨០ឆ្នាំ និងច្រើនឆ្នាំទៀត ដើម្បីសន្តិភាព ការអភិវឌ្ឍ និងសិទ្ធិមនុស្ស»** ដែលបង្ហាញពីស្មារតីរក្សានិរន្តភាពទៅមុខ និងកិច្ចសហប្រតិបត្តិការសំដៅគាំទ្រដល់ដំណើរការរបស់ស្ថាប័នកំពូលពិភពលោកដ៏ឧត្តុង្គឧត្តមនេះឱ្យនៅបន្តស្ថិតនៅជាពន្លឺនៃក្តីសង្ឃឹមសម្រាប់មនុស្សជាតិទាំងមូល។

មូលបទសម្រាប់ឆ្នាំនេះមិនមែនគ្រាន់តែជាពាក្យស្លោកប៉ុណ្ណោះទេ ប៉ុន្តែគឺជាការក្រើនរំលឹកជាឧឡារិកនូវការសន្យាថា អង្គការសហប្រជាជាតិនឹងបន្តរស់រានបាន ដរាបណាតែយើងរួមគ្នាថែរក្សាឱ្យបានគង់វង្សនូវសាមគ្គីភាពរវាងប្រទេសនិងប្រទេស ក៏ដូចជាប្រជាជននិងប្រជាជន ហើយការវាស់វែងនូវភាពជោគជ័យគឺមិនត្រូវគិតចង្អៀតត្រឹមតែកម្រិតថ្នាក់ជាតិប៉ុណ្ណោះទេ តែត្រូវគិតអំពីសុខមាលភាពរួមនៃប្រជាពលរដ្ឋរបស់ពិភពលោកទាំងមូល។

ខ្ញុំមានកិត្តិយសជាអនេកដែលបានធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខមហាសន្និបាតដ៏ឧត្តុង្គឧត្តមនេះ ក្នុងឱកាសដ៏មានអត្ថន័យជាប្រវត្តិសាស្ត្រនៃការប្រារព្ធខួបលើកទី៨០ របស់អង្គការសហប្រជាជាតិ។ ក្រោយសង្គ្រាមសកលលោកកាលពីប្រាំបីទសវត្សរ៍កន្លងទៅ ក្រុមប្រទេសតូចធំទាំងឡាយបានរួបរួមគ្នាក្រោមចក្ខុវិស័យតែមួយគត់នោះគឺ សន្តិភាព ការអភិវឌ្ឍ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស អាចសម្រេចបានតែតាមរយៈសកម្មភាពរួមគ្នាប៉ុណ្ណោះ។

ទោះបីជាយ៉ាងនេះក្តី ខណៈពេលដែលយើងប្រមូលផ្តុំគ្នាដើម្បីអបអរសាទរដំណាក់កាលប្រវត្តិសាស្ត្រដ៏សំខាន់នេះ គោលការណ៍ពហុភាគីកំពុងប្រឈមមុខនឹងការសាកល្បងដ៏ធ្ងន់ធ្ងរបំផុតមិនធ្លាប់មានរាប់ជំនាន់

មកហើយ។ ការបែងចែកក្នុងភូមិសាស្ត្រនយោបាយមានសភាពកាន់តែជ្រាលជ្រៅ ខណៈដែលការប្រកួតប្រជែងរវាងអំណាចធំៗបានធ្វើឱ្យក្រុមប្រឹក្សាសន្តិសុខជួបនឹងបញ្ហាអសមត្ថភាពជាញឹកញាប់ ដែលទុកឱ្យវិបត្តិជាច្រើននៅទូទាំងពិភពលោកមិនត្រូវបានដោះស្រាយ ហើយជីវិតរាប់លាននាក់ត្រូវប្រឈមនឹងគ្រោះមហន្តរាយ។ ពិភពលោកសព្វថ្ងៃនេះកំពុងប្រឈមមុខនឹងការពិតដ៏អាក្រក់គឺ "អំណាចក្លាយជាសិទ្ធិ" និង "អ្នកខ្លាំងអាចធ្វើអ្វីតាមដែលគេចង់ ខណៈដែលអ្នកខ្សោយត្រូវទទួលរងនូវអ្វីដែលពួកគេត្រូវតែទទួលរង"។ ការពឹងអាស្រ័យគ្នាទៅវិញទៅមកលែងជាគ្រឹះនៃសន្តិភាពទៀតហើយ តែគឺជាឧបករណ៍សម្រាប់ធ្វើការគំរាមកំហែង និងបង្ខិតបង្ខំ។

ប្រសិនបើយើងពិតជាមានជំនឿថា «យើងប្រសើរជាងមុនក្នុងការរួមគ្នា» នោះយើងត្រូវតែពង្រឹងឡើងវិញនូវទំនុកចិត្តចំពោះស្ថាប័នពហុភាគី ត្រូវវិនិយោគលើកិច្ចការទូតផ្តោតសំដៅការពារទប់ស្កាត់ និងធានាឱ្យអង្គការសហប្រជាជាតិមានសមត្ថភាពទាំងផ្នែកនយោបាយ និងហិរញ្ញវត្ថុ ដើម្បីឆ្លើយតបឱ្យបានយ៉ាងម៉ឺងម៉ាត់ចំពោះបញ្ហាប្រឈមទាំងចាស់ និងថ្មី។

## លោកជំទាវប្រធាន

## ឯកឧត្តម លោកជំទាវ លោក លោកស្រី

ខ្ញុំសូមអនុញ្ញាតលើកមតិអំពីសន្តិភាព ដោយផ្អែកលើបទពិសោធន៍ជាក់ស្តែង។ អស់រយៈពេលជាច្រើនទសវត្សរ៍ សង្គ្រាមនិងអំពើប្រល័យពូជសាសន៍បានបន្សល់ទុកនូវស្លាកស្នាមដល់ប្រជាពលរដ្ឋកម្ពុជា និងបំផ្លាញប្រទេសជាតិរបស់យើង។ ការសន្ទនា និងការមិនជ្រើសរើសសង្គ្រាម ដោយរដ្ឋបុរសឆ្នើមចំនួនពីររូប គឺព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតា **នរោត្តម សីហនុ** និងសម្តេចតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីកម្ពុជា ដែលជាថ្នាក់ដឹកនាំកំពូលប្រកបដោយប្រាជ្ញាឈ្លាសវៃ ឆន្ទៈមោះមុត និងស្មារតីស្នេហាជាតិពិតប្រាកដ បានធ្វើឱ្យមាននូវដំណើរការសន្តិភាព និងការផ្សះផ្សាជាតិឡើងវិញ។ នៅទីបំផុត សន្តិភាពត្រូវសម្រេចបានតាមរយៈគោលនយោបាយឈ្នះ-ឈ្នះ របស់សម្តេចតេជោ **ហ៊ុន សែន** ដែលបានបញ្ចប់សង្គ្រាមរយៈពេល ៣០ឆ្នាំ ដោយពុំមានការបាញ់កាំភ្លើងសូម្បីតែមួយគ្រាប់។

យើងខ្ញុំនៅតែដឹងគុណជានិច្ចចំពោះបណ្តាប្រទេសជាច្រើន រួមទាំងតាមរយៈបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ (UNPKO) ដែលបានផ្តល់ការគាំទ្រដល់កម្ពុជាក្នុងអំឡុងនៃដំណើរការស្វែងរកសន្តិភាព។ នៅតាមទីក្រុង និងភូមិឋានទូទាំងប្រទេសកម្ពុជា ពាក្យថា «**យើងអរគុណសន្តិភាព**» មិនមែនដាក់សម្រាប់ការតុបតែងនោះទេ ប៉ុន្តែជាការក្រើនរំលឹកជាប់ជាប្រចាំថ្ងៃថា សន្តិភាពគឺជាទ្រព្យសម្បត្តិដ៏វិសេសវិសាលបំផុតរបស់ប្រទេសជាតិយើង។

សន្តិភាពអាចឱ្យយើងកសាងឡើងវិញងើបចេញផុតពីផេះផង់នៃការបំផ្លិចបំផ្លាញទាំងស្រុង។ មុនការផ្ទុះរាលដាលជំងឺរាតត្បាត សេដ្ឋកិច្ចរបស់យើងបានសម្រេចកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ៧% ដែលធ្វើឱ្យកម្ពុជាអាចនឹងឈានចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចបំផុត នៅឆ្នាំ២០២៩។ តាមរយៈវឌ្ឍនភាពនេះ ប្រជាជនរាប់លាននាក់បានរួចផុតពីភាពក្រីក្រក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយ។ យើងសូមថ្លែងអំណរគុណចំពោះដៃគូរបស់យើងទាំងឡាយ ដែលកំពុងគាំទ្រកម្ពុជាឱ្យឈានចាកចេញពីឋានៈនេះដោយរលូនតាមរយៈពាណិជ្ជកម្មបើកចំហ និងបរិយាបន្ន។

ដោយអនុវត្តតាមយុទ្ធសាស្ត្របញ្ចកោណ (Pentagonal Strategy) កម្ពុជានៅតែបន្តរៀបចំរបៀបវារៈអភិវឌ្ឍន៍របស់ខ្លួនឱ្យស៊ីគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals)។ កាលពីឆ្នាំមុន យើងបានដាក់ចេញជាផ្លូវការនូវយុទ្ធសាស្ត្រដើម្បីសម្រេចបាន

សេវាសុខាភិបាលគ្រប់ដណ្ដប់ជាសកលក្នុងប្រទេសកម្ពុជាត្រឹមឆ្នាំ២០៣៥ និងបង្កើនលទ្ធភាពឱ្យយុវជនរបស់យើងទទួលបានការអប់រំប្រកបដោយគុណភាព សម្រាប់ពិភពលោកដែលកំពុងមានការប្រែប្រួល។ បច្ចុប្បន្ន មានស្ត្រីកាន់តំណែងថ្នាក់ដឹកនាំក្នុងជួររាជរដ្ឋាភិបាល និងសហគ្រាសឯកជន ក្នុងកម្រិតមួយដែលមិនធ្លាប់មានពីមុនមក ដែលបានជួយពង្រឹងសង្គមរបស់យើង។

យើងនៅតែបន្តពង្រឹងអភិបាលតាមបែបប្រជាធិបតេយ្យ ដោយដឹងថាការអភិវឌ្ឍ និងសិទ្ធិមនុស្សគឺជាសសរស្តម្ភដែលមិនអាចកាត់ផ្ដាច់ចេញពីគ្នាបានទេ សម្រាប់សន្តិភាពយូរអង្វែង។

ពាក់ព័ន្ធនឹងសកម្មភាពអាកាសធាតុ ដែលជាការសាកល្បងរួមដ៏ធំបំផុតមួយសម្រាប់មនុស្សជាតិ កម្ពុជាបានដាក់ចេញការរួមចំណែករបស់ជាតិ (NDC) ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ កាលពីខែមិថុនាឆ្នាំនេះ យើងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការអភិរក្សនិងការប្រើប្រាស់ជីវៈចម្រុះសមុទ្រប្រកបដោយចីរភាពនៅក្រៅដែនយុត្តាធិការជាតិ (BBNJ) និងបានតម្កល់លិខិតុបករណ៍ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង កាលពីដើមខែនេះ។ ជំហានទាំងនេះឆ្លុះបញ្ចាំងពីការជឿជាក់របស់យើងថា ការថែរក្សាបរិស្ថានគឺជាកាតព្វកិច្ចសកល និងជាកាតព្វកិច្ចសីលធម៌។

ជាមួយនឹងសន្តិភាពពេញលេញ កម្ពុជាអាចរួមចំណែកដល់ការកសាង និងការថែរក្សាសន្តិភាព នៅទូទាំងពិភពលោក។ កម្ពុជាបានប្រែក្លាយពីប្រទេសមួយដែលធ្លាប់ទទួលកងបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ទៅជាអ្នករួមចំណែកដ៏មុតមាំចំពោះសន្តិសុខសកល។ ចាប់តាំងពីឆ្នាំ ២០០៦ យើងបានបញ្ជូនកងកម្លាំងថែរក្សាសន្តិភាពជាង ១០,០០០ នាក់ ក្នុងនោះមានស្ត្រីជាង ៨០០ នាក់ ទៅចូលរួមក្នុងបេសកកម្មរបស់អង្គការសហប្រជាជាតិចំនួនដប់ នៅទូទាំងពិភពលោក។ កងកម្លាំងរបស់យើងបានការពារជនស៊ីវិល បោសសំអាតមីន និងគាំទ្រដល់ការកសាងឡើងវិញនូវសហគមន៍ដែលរងគ្រោះដោយសារសង្គ្រាម។ បច្ចុប្បន្នយើងជាសមាជិកដ៏សកម្មមួយ នៃគណៈកម្មការកសាងសន្តិភាព ដែលជួយប្រទេសងើបចេញពីជម្លោះ ក្នុងការបង្កើតស្ថាប័ន និងលើកកម្ពស់ការផ្សះផ្សា។

## លោកជំទាវប្រធាន

## ឯកឧត្តម លោកជំទាវ លោក លោកស្រី

ការវិវត្តប្រែប្រួលរបស់ប្រទេសកម្ពុជា គឺជាសក្ខីភាពនៃអត្ថន័យមូលបទរបស់មហាសន្និបាតអង្គការសហប្រជាជាតិលើកទី៨០ ពេលគឺជាប្រទេសដែលធ្លាប់ត្រូវការសន្តិភាព បានក្លាយជាប្រទេសដែលជួយផ្តល់សន្តិភាព និងស្ថិរភាពសម្រាប់ប្រទេសដទៃទៀត។ ហេតុនេះ ខ្ញុំពិតជាមានសេចក្តីឈឺចាប់ជាពន់ពេកក្នុងការជម្រាបជូនមហាសន្និបាតថ្ងៃនេះថា សន្តិភាពនៅក្នុងប្រទេសរបស់យើងខ្ញុំផ្ទាល់ ដែលទទួលបានដោយលំបាក ហើយដែលយើងស្រលាញ់យ៉ាងជ្រាលជ្រៅ និងចែករំលែកអស់ពីដួងចិត្តនៅជុំវិញពិភពលោក បច្ចុប្បន្នកំពុងរងការគំរាមកំហែង មិនមែនដោយសារការបែកបាក់ផ្ទៃក្នុងដូចពីអតីតកាលនោះទេ តែគឺ ដោយសារជម្លោះព្រំដែនជាមួយប្រទេសជិតខាងមួយ។

កម្ពុជាអរគុណណាស់ចំពោះបទឈប់បាញ់ តាមរយៈការសម្របសម្រួលរបស់ឯកឧត្តមប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ ដែលបញ្ឈប់បានដោយប្រសិទ្ធភាពនូវការប៉ះទង្គិចប្រដាប់អាវុធ ដែលបានធ្វើឱ្យប្រជាជនស្លូតត្រង់បាត់បង់ជីវិត រងរបួស រងការបំផ្លិចបំផ្លាញ និងរាប់សែននាក់ក្លាយជាជនភៀសសឹក។

ដូចប្រទេសអាមេនី និងអាស៊ែបៃហ្សង់ កម្ពុជាបានស្នើបេក្ខភាពឯកឧត្តមប្រធានាធិបតី ដូណាល់ ត្រាំ សម្រាប់ការទទួលពានរង្វាន់ណូបែលសន្តិភាពចំពោះតួនាទីដ៏សំខាន់នៅក្នុងជំហានដ៏ចាំបាច់ដើម្បីសន្តិភាព។ ទោះជាយ៉ាងនេះក្តី បទឈប់បាញ់នៅមានភាពផុយស្រួយ ទោះបីជាមានការប្តេជ្ញាចិត្តពីប្រទេសទាំងពីរក្នុងការអនុវត្តតាមយ៉ាងម៉ឺងម៉ាត់តាមលក្ខខណ្ឌនានានៃបទឈប់បាញ់ ដើម្បីកសាងទំនុកចិត្ត និងស្តារស្ថានភាព

ដូចដើមឡើងវិញក៏ដោយ និងលទ្ធផលជាវិជ្ជមាននៃកិច្ចប្រជុំបន្តបន្ទាប់បានរៀបចំ និងសម្របសម្រួលដោយប្រទេស ម៉ាឡេស៊ី ដែលជាប្រធានអាស៊ាន។

ជាការសំខាន់បំផុតដែលការគោរពលើពាក្យពេចន៍ និងស្មារតីនៃកិច្ចព្រមព្រៀង ត្រូវតែស្របគ្នាជាមួយនឹងការអនុវត្តជាក់ស្តែង។ គួរឱ្យសោកស្តាយ ការបន្តសកម្មភាពឯកតោភាគីដើម្បីយកអធិបតេយ្យទឹកដីពីសំណាក់ប្រទេសជិតខាងរបស់កម្ពុជា ដោយប្រើកងកម្លាំងជំនួសឱ្យយន្តការដែលបានព្រមព្រៀងគ្នា ផែនទីឯកតោភាគីជំនួសឱ្យផែនទីដែលមានការទទួលស្គាល់ជាអន្តរជាតិស្របតាមសន្ធិសញ្ញាដែលបានចងជាកាតព្វកិច្ចសម្រាប់ប្រទេសទាំងពីរ និងសកម្មភាពរាប់មិនអស់ដែលបំផ្លាញដល់កិច្ចខិតខំប្រឹងប្រែងកសាងទំនុកចិត្ត និងសន្តិភាព។

បញ្ហាព្រួយបារម្ភបំផុតនោះ គឺការបណ្តេញពលរដ្ឋកម្ពុជាដោយបង្ខំ ការគំរាមកំហែងប្រើច្បាប់ជាតិ (ច្បាប់អាជ្ញាសឹក) ប្រឆាំងនឹងពលរដ្ឋខ្មែរ និងការបណ្តេញប្រជាជនកម្ពុជារាប់រយគ្រួសារទៀតចេញពីភូមិដ្ឋានដែលពួកគេបានរស់នៅអាស្រ័យផលអស់រាប់ទសវត្សរ៍មកហើយ។ ការចូលកាន់កាប់ទឹកដីនៅលើតំបន់ដែលមិនទាន់ត្រូវបានខណ្ឌសីមាព្រំដែន បង្ហាញឱ្យឃើញយ៉ាងជាក់ច្បាស់ពីការមិនគោរពចំពោះលក្ខខណ្ឌនៃបទឈប់បាញ់ ក៏ដូចជាកិច្ចព្រមព្រៀងទាំងសងខាងផ្សេងៗទៀត ពាក់ព័ន្ធការដោះស្រាយបញ្ហាព្រំដែនផងដែរ។

ទង្វើខាងលើនេះបានរំលោភលើអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា ហើយជាមួយគ្នានេះសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ប្រជាជនកម្ពុជាជាច្រើនក៏ត្រូវបានបំពាន។

កម្ពុជាបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវបទឈប់បាញ់ ដោយបង្ហាញសុឆន្ទៈ និងតម្លាភាពពេញលេញក្នុងការអនុវត្តលក្ខខណ្ឌនៃបទឈប់បាញ់ និងរក្សាភាពអត់ធ្មត់ជាទីបំផុតចំពោះមុខការបង្ករឿង និងការរំលោភបំពានម្តងហើយម្តងទៀត។ ជាក់ស្តែង នៅព្រឹកមិញនេះ មានការវាយប្រហារមួយកន្លែងដោយមិនញញើតនៅជិតទីតាំងដ៏រសើបមួយ ដោយចោទប្រកាន់ថា កងកម្លាំងរបស់កម្ពុជាបានបើកការបាញ់ប្រហារមុន។ យើងបដិសេធយ៉ាងម៉ឺងម៉ាត់ចំពោះការចោទប្រកាន់នេះ។ កងទ័ពរបស់យើងមិនមាន និងក៏មិនមានការបាញ់តបតវិញ សូម្បីតែបានបដិសេធពីសកម្មភាពសងសឹកណាមួយ ដោយបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងចំពោះសន្តិភាព។

ក្នុងស្មារតីដូចកាលពីបានបញ្ចប់សង្គ្រាមជិតបីទសវត្សរ៍កន្លងមក កម្ពុជាសូមអំពាវនាវឱ្យមានកិច្ចសន្ទនា ការដោះស្រាយជម្លោះដោយសន្តិវិធី ដោយគោរពយ៉ាងម៉ឺងម៉ាត់ និងស្មោះត្រង់ចំពោះលក្ខខណ្ឌដែលបានព្រមព្រៀងនៃបទឈប់បាញ់ ការគោរពពេញលេញចំពោះកិច្ចព្រមព្រៀងទ្វេភាគី ច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន។

កម្ពុជាស្នើសុំដោយស្មោះត្រង់នូវការបន្តគាំទ្រ និងការសម្របសម្រួលរបស់ប្រធានអាស៊ាន និងប្រទេសសមាជិកអាស៊ាន, អគ្គលេខាធិការ និងស្ថាប័នពាក់ព័ន្ធនៃអង្គការសហប្រជាជាតិ ព្រមទាំងថ្នាក់ដឹកនាំជុំវិញពិភពលោក ដើម្បីជួយបន្ធូរបន្ថយភាពតានតឹង លើកទឹកចិត្តដល់ការដោះស្រាយជម្លោះដោយសន្តិវិធី និងទប់ស្កាត់ការកើតឡើងនូវសោកនាដកម្មបន្ថែមទៀត។

កម្ពុជាជាប្រទេសតូច ផ្តោតលើការកសាងសេដ្ឋកិច្ចរបស់យើងឡើងវិញ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។ យើងមិនបង្កការគំរាមកំហែងដល់អធិបតេយ្យរបស់ប្រទេសណាមួយឡើយ។ ខណៈដែលយើងត្រូវតែការពារជានិច្ចនូវ ឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីរបស់យើង ការប្រើកម្លាំងគឺជាជំរើសចុងក្រោយបំផុត។

កម្ពុជានឹងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីស្តារទំនុកចិត្ត និងប្រក្រតីភាព លើកកម្ពស់ការរួមរស់ជាមួយគ្នាប្រកបដោយសុខដុមរមនា និងទំនាក់ទំនងអ្នកជិតខាងល្អ និងប្រែក្លាយតំបន់ព្រំដែនទៅជាតំបន់សន្តិភាព

មិត្តភាព កិច្ចសហប្រតិបត្តិការ និងវិបុលភាពរួមគ្នា។

## លោកជំទាវប្រធាន

## ឯកឧត្តម លោកជំទាវ លោក លោកស្រី

ដើម្បីលើកស្ទួយនូវចក្ខុវិស័យរបស់ស្ថាបនិកអង្គការសហប្រជាជាតិ និងឆ្លើយតបចំពោះស្ថានការណ៍ជាក់ស្តែងនាពេលបច្ចុប្បន្ន ចាំបាច់ត្រូវតែមានការកែទម្រង់អង្គការដ៏ឧត្តមនេះ។ កម្ពុជាគាំទ្រកំណែទម្រង់ដែលមានលក្ខណៈជាក់ស្តែង និងតាមដំណាក់កាលបន្តបន្ទាប់ សំដៅជួយពង្រឹងប្រសិទ្ធភាព តែមិនធ្វើឱ្យប៉ះពាល់ដល់ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិឡើយ។

កម្ពុជាយល់ថាអាទិភាពសំខាន់គឺរួមមាន៖

- ការពង្រឹងអំណាចនៃយន្តការការទូតដើម្បីបញ្ចៀសជម្លោះ និងសម្រុះសម្រួល ដោយផ្តល់ឧបករណ៍បន្ថែមដល់អង្គការសហប្រជាជាតិ សម្រាប់ដោះស្រាយវិបត្តិឱ្យបានមុនពេលផ្ទុះឡើង។
- ការពង្រឹងមហាសន្និបាតអ.ស.ប. ដែលជាស្ថាប័នមានលក្ខណៈតំណាងបំផុត ដោយត្រូវធ្វើយ៉ាងណាឱ្យសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត មានសមត្ថភាពខ្លាំងជាងមុនក្នុងការត្រួតពិនិត្យតាមដានលើការអនុវត្ត និងមានទម្ងន់ផ្នែកសីលធម៌ខ្លាំងជាមុន។
- ការបង្កើនចំនួនអាសនៈសមាជិកមិនអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខ ដើម្បីឆ្លុះបញ្ចាំងឱ្យកាន់តែប្រសើរជាងមុននូវស្ថានភាពពិភពលោកពហុប៉ូលនាពេលបច្ចុប្បន្ននេះ និងដើម្បីពង្រឹងនីត្យានុកូលភាពនៃក្រុមប្រឹក្សាសន្តិសុខ។
- ពង្រឹងបេសកកម្មថែរក្សាសន្តិភាព និងបេសកកម្មឃ្លាំមើលតាមបន្ទាត់ព្រំដែន ជាពិសេសនៅតំបន់ជម្លោះ ដើម្បីឱ្យរដ្ឋតូចៗទទួលបាននូវសិទ្ធិស្មើគ្នាក្នុងយន្តការសម្រុះសម្រួល និងការការពារ។
- វិធានការបំពេញបន្ថែមមួយចំនួនទៀត ដូចជា ការផ្តល់មូលនិធិ, បច្ចេកវិទ្យា និងការកែសម្រួលផ្នែកច្បាប់ជាជំហានៗ នឹងអាចប្រែក្លាយគោលការណ៍កំណែទម្រង់ដ៏ធំទៅជាវឌ្ឍនភាពជាក់ស្តែង។

សម្រាប់ប្រទេសដូចជាកម្ពុជា អំណាចដ៏ធំបំផុតរបស់អង្គការសហប្រជាជាតិ មិនមែនជាអំណាចបង្ខិតបង្ខំទេ ប៉ុន្តែជាអំណាចខាងសីលធម៌ ភាពស្របច្បាប់ និងអំណាចកោះប្រជុំ ដែលនឹងអាចជួយការពារប្រទេសតូចៗ និងរក្សាបាននូវសន្តិភាព។

ដើម្បីអបអរសាទរខួបលើកទី៨០ នៃអង្គការសហប្រជាជាតិ យើងទាំងអស់គ្នាត្រូវគោរពចក្ខុវិស័យរបស់ស្ថាបនិកអង្គការអន្តរជាតិនេះ ដោយជ្រើសយកកិច្ចសហប្រតិបត្តិការជំនួសការប្រឈមមុខគ្នា ការសន្ទនាជំនួសការបែកបាក់ និងក្តីសង្ឃឹមជំនួសភាពអស់សង្ឃឹម។

កម្ពុជាត្រៀមខ្លួនក្នុងការសម្រេច «ភាពប្រសើរឡើងជាមួយគ្នា» ដោយសហការជាមួយរដ្ឋសមាជិកទាំងអស់, ប្រព័ន្ធអង្គការសហប្រជាជាតិ និងដៃគូរបស់យើងនៅទូទាំងពិភពលោក ដើម្បីធានាថាក្នុងអនាគតរាប់ទសវត្សរ៍ទៅមុខទៀតនឹងពោរពេញទៅដោយសន្តិភាព ការអភិវឌ្ឍប្រកបដោយចីរភាព និងសេចក្តីថ្លៃថ្នូរដែលមិនអាចកាត់ថ្លៃបានសម្រាប់មនុស្សគ្រប់រូប៕

**សូមអរគុណ។**